

## អំពី

### អង្គការសិល្បៈខ្មែរអមតៈ

អង្គការសិល្បៈខ្មែរអមតៈ (សខអ) គាំទ្រសិល្បករនិងអង្គការសិល្បៈគ្រប់ទម្រង់ ដោយផ្តោតលើការពង្រឹង និងអភិវឌ្ឍវិស័យសិល្បៈឱ្យកាន់តែទូលំទូលាយ។ សខអ ក៏ជួយផ្តល់សេវាគ្រប់គ្រងប្រតិបត្តិការហិរញ្ញវត្ថុនិងរដ្ឋបាលប្រចាំឆ្នាំ ដល់អង្គការសិល្បៈដែលទើបនឹងបង្កើតឡើង ដូចជាជួយសម្របសម្រួលការអភិវឌ្ឍអង្គភាពនិងកម្មវិធីទៅតាមពេលវេលាជាក់លាក់ណាមួយដែលបានព្រមព្រៀងគ្នា (នេះហៅថា កម្មវិធីរុងរឿង)។

កម្មវិធីស្នូលរបស់យើងរួមមាន៖ ការផ្តល់មូលនិធិដល់សិល្បករ (ឧ. សម្រាប់ការបង្កើតស្នាដៃសិល្បៈថ្មី, សម្រាប់បង្កើតគម្រោងសហគមន៍  និងសម្រាប់ការធ្វើដំណើរទៅក្រៅប្រទេសដើម្បីបង្កើតបណ្តាញការងារ), អាហារូបករណ៍សម្រាប់អភិវឌ្ឍអាជីពសិល្បៈ, និងការរៀបចំការសម្តែងឬព្រឹត្តិការណ៍សិល្បៈផ្សេងៗនៅតាមតំបន់ជនបទ ដើម្បីឱ្យមនុស្សកាន់តែច្រើនមានឱកាសបានចូលរួម និងស្គាល់ទាំងទម្រង់សិល្បៈបុរាណនិងសហសម័យ។ យើងក៏រៀបចំកម្មវិធីជ័យលាភីអមតៈប្រចាំឆ្នាំ ដើម្បីអបអរដល់អ្នកទទួលបានមូលនិធិនិងអាហារូបករណ៍។

អង្គការសិល្បៈខ្មែរអមតៈ និង មជ្ឈមណ្ឌលវប្បធម៌មេគង្គ (www.mekongculturalhub.org) ជាសមាជិករបស់ សិល្បៈអមតៈអន្តរជាតិ (www.livingartsinternational.org/) ដែលជាអង្គការអន្តរជាតិមួយមានជំនឿថា សង្គមមួយអាចរីកចម្រើនពេញលេញទៅបាន ដោយមានការចូលរួមពីសិល្បៈ។



### ជឿជាក់

យើងជឿជាក់ថា សង្គមមួយអាចរីកចម្រើនពេញលេញទៅបានដោយមានការចូលរួមពីសិល្បៈ។



### ទស្សនវិស័យ

យើងមានទស្សនវិស័យថា សិល្បៈ និងវប្បធម៌មានសារៈសំខាន់ដែលមិនអាចខ្វះបានសម្រាប់អនាគតដ៏រុងរឿងរបស់កម្ពុជា។



### បេសកកម្ម

សិល្បៈខ្មែរអមតៈមានបេសកកម្មដើរតួជាកត្តាជំរុញនៅក្នុងវិស័យសិល្បៈដ៏រស់រវើក ដែលញុំាងចិត្តអ្នកជំនាន់ថ្មី។

> “ *មូលនិធិដំឡើងស្នាដៃថ្មីបានផ្តល់នូវការជ្រោមជ្រែង ហើយជំរុញឱ្យខ្ញុំអាចឆ្លងកាត់នូវឧបសគ្គដោយទំនុកចិត្ត ហើយអាចបន្តការងារក្នុងក្តីស្រមៃរបស់ខ្ញុំ។*



វីរៈ វីនិច
អ្នកទទួលបានមូលនិធិដំឡើងស្នាដៃថ្មីឆ្នាំ ២០២៤



> “ *ខ្ញុំបានទទួលថវិកា ការបណ្តុះបណ្តាល និងបទពិសោធថ្មីៗ ដែលជួយពង្រឹងសមត្ថភាព និងទំនុកចិត្តរបស់ខ្ញុំឱ្យកាន់តែប្រសើរឡើង។ សខអ ជួយឱ្យខ្ញុំអាចចូលរួមអភិវឌ្ឍប្រទេសតាមរយៈសិល្បៈ។*

ហ៊ុន ស្មើ
អ្នកទទួលអាហារូបករណ៍សិល្បៈអមតៈ អាន ចនផន ឆ្នាំ ២០២៤

សិល្បៈខ្មែរអមតៈ

**ស្វែងយល់បន្ថែមនៅលើ**

- Cambodian Living Arts (CLA)
- CambodianLivingArts
- CamboLivingArts
- www.cambodianlivingarts.org
- info@cambodianlivingarts.org
- +855 23 986 032

ស្កេនដើម្បីទទួលបានព័ត៌មានថ្មីៗអំពីឱកាសក្នុងវិស័យសិល្បៈ!

សិល្បៈខ្មែរអមតៈ



# គោលដៅយុទ្ធសាស្ត្រអាទិភាព
## របស់អង្គការសិល្បៈខ្មែរអមតៈ ២០២៦ - ២០៣០

*បង្កើតអនាគតដ៏រស់រវើក សម្រាប់វិស័យសិល្បៈកម្ពុជា!*

# សារពីនាយិកាប្រតិបត្តិ

យ៉ុន សុខខន



*ខណៈយើងទាំងអស់គ្នាកំពុងប្រឹងប្រែងរួមគ្នាប្រឈមមុខនឹងបញ្ហាជាសកលនានាក្នុងពេលបច្ចុប្បន្ន នាងខ្ញុំនៅតែមានសុទិដ្ឋិនិយម និងក្តីរំភើបចំពោះគោលដៅយុទ្ធសាស្ត្រអាទិភាព ៥ ឆ្នាំ (២០២៦–២០៣០) របស់យើង។ បើយើងក្រឡេកមើលការងារដែលសិល្បៈខ្មែរអមតៈបានធ្វើអស់រយៈកាលជិត ៣ ទសវត្សរ៍មកនេះ ខ្ញុំពិតជាមានភាពស្ញប់ស្ញែងចំពោះវិវឌ្ឍនាការនៃការងាររបស់យើង ដែលមានភាពស្របគ្នាជាមួយនឹងបរិបទវប្បធម៌ក្នុងជំនាន់ថ្មីនៃសង្គមកម្ពុជា។ យើងតែងតែបត់បែនខ្លួនឯងដើម្បីឆ្លើយតបនឹងតម្រូវការរបស់សហគមន៍ ដោយធានាថា ការងារគាំទ្រវិស័យសិល្បៈរបស់យើង ដើរទន្ទឹមគ្នានឹងស្ថានភាពជាក់ស្តែងដែលសិល្បករកម្ពុជាកំពុងប្រឈម ព្រមទាំងចូលរួមចំណែកឆ្លុះបញ្ចាំងអំពីទិដ្ឋភាពសង្គមឱ្យកាន់តែមានភាពទូលំទូលាយតាមរយៈវិញ្ញត្តិសិល្បៈ។*

## គោលដៅ

### យុទ្ធសាស្ត្រអាទិភាព

- ពង្រឹងគុណភាពសិល្បៈសហសម័យនៅកម្ពុជា
- បន្លឺសំឡេងសិល្បករ ជាពិសេសតាមរយៈប្រព័ន្ធឌីជីថល
- កសាងសមត្ថភាពសិល្បករឯករាជ្យ ប្រតិបត្តិករសិល្បៈវប្បធម៌ និងស្ថាប័នតូចៗ ដើម្បីឆ្ពោះទៅរកនិរន្តរភាពផ្នែកប្រតិបត្តិការ
- ជំរុញកិច្ចសហការទាំងថ្នាក់តំបន់និងអន្តរជាតិ ដើម្បីពង្រឹងវិស័យសិល្បៈវប្បធម៌

## វិធីសាស្ត្រ

### ដើម្បីសម្រេចគោលដៅយុទ្ធសាស្ត្រ



កម្មវិធីផ្តល់មូលនិធិ



កម្មវិធីបណ្តុះបណ្តាលនិងអភិវឌ្ឍ



កម្មវិធីសិល្បៈនិងសហគមន៍



កម្មវិធីរុងរឿង

## កម្មវិធីស្នូល

### របស់យើង

#### កម្មវិធីផ្តល់មូលនិធិ





កម្មវិធីផ្តល់មូលនិធិរបស់យើងត្រូវបានបង្កើតឡើងក្នុងគោលបំណងជ្រោមជ្រែងដល់ការបង្កើតស្នាដៃថ្មី ការពង្រឹងគម្រោងវប្បធម៌ និងការពង្រីកឱកាសសម្រាប់សិល្បករកម្ពុជាទាំងក្នុងស្រុក និងអន្តរជាតិ។

**មូលនិធិដាំដុះ**

សម្រាប់ជួយដល់សិល្បករនិងប្រតិបត្តិករវប្បធម៌ ព្រមទាំងជួយផ្សព្វផ្សាយ និងជួយបន្លឺសំឡេងរបស់ពួកគេតាមរយៈវេទិកាឌីជីថល និងវេទិកាសាធារណៈ។

**មូលនិធិចល័ត**

សម្រាប់ជួយដល់សិល្បករនិងប្រតិបត្តិករវប្បធម៌គ្រប់ទម្រង់ ដើម្បីអភិវឌ្ឍគំនិត បណ្តាញ និងជំនាញ តាមរយៈការចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា សន្និសីទ មហោស្រព បង្ហាញលទ្ធផលនៃការស្រាវជ្រាវ ចូលរួមគម្រោងនិវាសដ្ឋាន។

**មូលនិធិដំឡើងស្នាដៃថ្មី**

សម្រាប់ជួយដល់សិល្បកររៀមច្បងនិងជំនាន់ថ្មីក្នុងការអភិវឌ្ឍជំនាញច្នៃប្រតិដ្ឋ ភាពជាអ្នកដឹកនាំ និងគម្រោង តាមរយៈការណែនាំផ្ទាល់ ការបង្កើតស្នាដៃថ្មីៗ និងសិក្ខាសាលាបណ្តុះជំនាញ ជាមួយអ្នកជំនាញឯកទេសថ្នាក់តំបន់ ដោយផ្តោតលើដំណើរការនៃការបង្កើតស្នាដៃដែលមានគុណភាពខ្ពស់ និងការបង្ហាញស្នាដៃទាំងនោះជាសាធារណៈ។

#### កម្មវិធីសិល្បៈនិងសហគមន៍





កម្មវិធីនេះនាំយកទស្សនីយភាពសិល្បៈទៅបង្ហាញជូនប្រជាជនដែលមិនសូវមានឱកាសចូលរួមសកម្មភាពសិល្បៈ ជាពិសេសនៅតាមតំបន់ជនបទ តាមរយៈកម្មវិធីប្រគំតន្ត្រីតាមភូមិ សម្តែង សិក្ខាសាលា និងកម្មវិធីសម្តែងសិល្បៈតាមខេត្ត។

**ការប្រគំតន្ត្រីតាមភូមិ**

យើងរៀបចំកម្មវិធីប្រគំតន្ត្រីនៅតាមសហគមន៍ឆ្ងាយៗ ដែលប្រជាជនមានឱកាសតិចតួចក្នុងការចូលរួមព្រឹត្តិការណ៍សិល្បៈ។

**បទបង្ហាញតន្ត្រី**

យើងផ្សព្វផ្សាយពីឧបករណ៍តន្ត្រីបុរាណខ្មែរកម្រៗនៅតាមភូមិនានាក្នុងប្រទេសកម្ពុជា តាមរយៈការធ្វើបទបង្ហាញនិងការជជែកសួរនាំផ្ទាល់។

**កម្មវិធីសម្តែងសិល្បៈតាមខេត្ត**

យើងនាំយកការសម្តែង កិច្ចពិភាក្សា និងសិក្ខាសាលាអន្តរកម្ម ទៅកាន់ខេត្តគោលដៅ ដើម្បីឱ្យសហគមន៍មូលដ្ឋានទទួលបានបទពិសោធជាមួយស្នាដៃថ្មី និងមានឱកាសសន្ទនាជាមួយសិល្បករដោយផ្ទាល់។

#### កម្មវិធីបណ្តុះបណ្តាលនិងអភិវឌ្ឍ





កម្មវិធីនេះជួយដល់សិល្បករក្នុងការពង្រឹងចំណេះដឹង ជំនាញច្នៃប្រតិដ្ឋ និងសមត្ថភាពដឹកនាំក្នុងវិស័យសិល្បៈ។

**អាហារូបករណ៍សិល្បៈអមតៈ អាន ចនផន**

សម្រាប់ជួយសិល្បករជំនាន់ថ្មីនិងអ្នកច្នៃប្រតិដ្ឋ ក្នុងការពង្រីកការអនុវត្តរបស់ពួកគេ ការបើកទស្សនៈរបស់ពួកគេឱ្យកាន់តែមានភាពទូលំទូលាយ និងការចូលរួមយ៉ាងសកម្មក្នុងទម្រង់សិល្បៈសហសម័យ តាមរយៈការផ្តល់ជំនួយហិរញ្ញវត្ថុ និងឱកាសអភិវឌ្ឍវិជ្ជាជីវៈ។

#### កម្មវិធីរុងរឿង





សខអ ផ្តល់ការគាំទ្រផ្នែកច្បាប់ ហិរញ្ញវត្ថុ និងរដ្ឋបាលដល់សិល្បករឯករាជ្យ និងអង្គការដែលទើបតែបង្កើតឡើង ជួយឱ្យពួកគេអាចទទួលបានមូលនិធិ និងពង្រឹងកម្មវិធី និងសមត្ថភាពរបស់អង្គភាព ជាពិសេសអំឡុងពេលដែលស្ថាប័នរបស់ពួកគេមិនទាន់មានភាពរឹងមាំនូវឡើយ។

## សូចនាករលទ្ធផល

- មានសិល្បករជាង ៣០ នាក់ និងសិស្សនិស្សិតចំនួន ២០ នាក់ ជារៀងរាល់ឆ្នាំ បានទទួលអាហារូបករណ៍ និងមូលនិធិ។
- ការផ្សព្វផ្សាយកម្មវិធីសិល្បៈទៅដល់ខេត្តចំនួន ៥ និងសហគមន៍ចំនួន ១៨ ដែលមានអ្នកចូលរួមចំនួនជាង ២០,០០០ នាក់ ជារៀងរាល់ឆ្នាំ។
- ក្នុងរយៈពេល ៨ ឆ្នាំកន្លងមកនេះ ចំនួនអ្នកទទួលបានមូលនិធិមានជាង ២០០ នាក់។
- មានសិល្បករចំនួនជាង១៥០នាក់ដែលទទួលបានការអភិវឌ្ឍខ្លួន តាមរយៈកម្មវិធីអាហារូបករណ៍ កម្មវិធីផ្លាស់ប្តូរវប្បធម៌ និងកម្មវិធីនិវាសនដ្ឋានទាំងក្នុងនិងក្រៅប្រទេស។